**Declassified to Public**
**12 June 2020**

លេខ៖ D304/12

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

**Kingdom of Cambodia**
**Nation Religion King**

**Royaume du Cambodge**
**Nation Religion Roi**

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា

Extraordinary Chambers in the Courts of Cambodia
Chambres extraordinaires au sein des Tribunaux cambodgiens

ការិយាល័យសហចៅក្រមស៊ើបអង្កេត

**Office of the Co-Investigating Judges**
**Bureau des co-juges d'instruction**

| ឯកសារដើម |
|---|
| **DOCUMENT RECEIVED/DOCUMENT REÇU** |
| ថ្ងៃ ខែ ឆ្នាំ (Date of receipt/date de reception): 31 / 08 / 2016 |
| ម៉ោង (Time/Heure): 13:00 |
| មន្ត្រីទទួលបន្ទុកសំណុំរឿង /Case File Officer/L'agent chargé du dossier: SANN RADA |

**សំណុំរឿងលេខ៖ ០០៤/០៧-០៩-២០០៩-អ.វ.ត.ក-ក.ស.ច.ស**

| | |
|---|---|
| ចំពោះមុខ ៖ | សហចៅក្រមស៊ើបអង្កេត |
| កាលបរិច្ឆេទ ៖ | ថ្ងៃទី ៣១ ខែ សីហា ឆ្នាំ ២០១៦ |
| ភាសា ៖ | អង់គ្លេស &ខ្មែរ [អង់គ្លេស ភាសាដើម] |
| ចំណាត់ថ្នាក់ឯកសារ ៖ | សម្ងាត់ |

# ដីកាសម្រេចលើសំណើរួមរបស់មេធាវីការពារក្តី សុំធ្វើចំណាត់ឯកសារឡើងវិញ ចំពោះសេចក្តីសម្រេច និងឯកសារពាក់ព័ន្ធនឹងសំណើសុំធនធាន

**ផ្ញើជូន៖**

**សហព្រះរាជអាជ្ញា**
ជា លាង
Nicholas KOUMJIAN

**មេធាវីការពារក្តី អោ អាន**
មុំ លុជ្ស
Richard ROGERS
Göran SLUITER

**មេធាវីការពារក្តី យឹម ទិត្យ**
សូ មុស្សេទ្រី
Suzana TOMANOVIĆ

**សហមេធាវីដើមបណ្តឹងរដ្ឋប្បវេណី**
ជេត វណ្ណលី
ហុង គីមសួន
គីម ម៉េងឃី
ឡោ ជុនធី
សំ សុគង់
ស៊ិន ស៊ីវ៉ន
ទី ស្រីនណា
វ៉េន ពៅ
Linda BEHNKE
Laure DESFORGES NZEPA
Herve DIAKIESE
Ferdinand DJAMMEN-NZEPA
Nicole DUMAS
Isabelle DURAND
Françoise GAUTRY
Emmanuel JACOMY
Martine JACQUIN
Christine MARTINEAU
Barnabe NEKUI
Lyma NGUYEN
Beini YE

I. **ប្រវត្តិនីតិវិធី**

១. ករណីខ្វែងយោបល់គ្នារវាងសហចៅក្រមស៊ើបអង្កេត (“ស.ច.ស”) នៅក្នុងសំណុំរឿងនេះ បានចុះបញ្ជីនៅថ្ងៃទី ២២ ខែ កុម្ភៈ ឆ្នាំ ២០១៣ ថ្ងៃទី ០៥ ខែ មេសា ឆ្នាំ ២០១៣ ថ្ងៃទី ២២ ខែ មករា ឆ្នាំ ២០១៥ និងថ្ងៃទី ២១ ខែ តុលា ឆ្នាំ ២០១៥។

២. នៅថ្ងៃទី ១៦ ខែ មីនា ឆ្នាំ ២០១៦ មេធាវីការពារក្តី អោ អាន បានដាក់សំណើស្នើ ស.ច.ស បង្គាប់ឱ្យអង្គភាពគាំពារការការពារក្តី (“អ.គ.ក”) បង្កើនថវិការបស់មេធាវីការពារក្តី ដើម្បីជួយសម្រួលការតែងតាំងអ្នកប្រឹក្សាច្បាប់អន្តរជាតិជាន់ខ្ពស់ម្នាក់ និងអ្នកប្រឹក្សាច្បាប់អន្តរជាតិជាន់ទាបម្នាក់បន្ថែមទៀត(“សំណើសុំធនធានរបស់ អោ អាន”)[1]។

៣. នៅថ្ងៃទី ១៨ ខែ មីនា ឆ្នាំ ២០១៦ ខ្ញុំបានចេញដីកាសម្រេចទី ១ លើសំណើនោះ ដែលក្នុងដីកាសម្រេចនេះខ្ញុំបានស្នើសុំព័ត៌មានលម្អិតថែមទៀតពីមេធាវីការពារក្តី ហើយបានអញ្ជើញ អ.គ.ក ឱ្យដាក់ចម្លើយតប[2]។ នៅថ្ងៃទី ២៤ ខែ មីនា ឆ្នាំ ២០១៦ មេធាវីការពារក្តី បានដាក់ព័ត៌មានលម្អិតបន្ថែម ហើយនៅថ្ងៃទី ៣១ ខែ មីនា ឆ្នាំ ២០១៦ អ.គ.ក បានដាក់ចម្លើយតប[3]។

៤. នៅថ្ងៃទី ២៦ ខែ មេសា ឆ្នាំ ២០១៦ ខ្ញុំបានចេញដីកាសម្រេចទី ២ លើសំណើសុំធនធានរបស់ អោ អាន ដែលនៅក្នុងដីកាសម្រេចនេះខ្ញុំបានស្នើសុំវិធានការថែមទៀតពី អ.គ.ក និងមេធាវី

---

[1]សំណុំរឿង 00៤ ឯកសារ D304 *សំណើបន្ទាន់សុំធនធានបន្ថែម* ថ្ងៃទី ១៦ ខែ មីនា ឆ្នាំ២០១៦ កថាខណ្ឌ ១៨។

[2]សំណុំរឿង 00៤ ឯកសារ D304/1 *ដីកាសម្រេចលើសំណើរបស់ អោ អាន សុំបង្គាប់ឱ្យអង្គភាពគាំពារការការពារក្តី ផ្តល់ធនធានបន្ថែម* ថ្ងៃទី ១៨ ខែ មីនា ឆ្នាំ២០១៦។

[3]សំណុំរឿង 00៤ ឯកសារ D304/2 *ការផ្តល់ជូនបន្ទាន់នូវព័ត៌មានលម្អិតបន្ថែមអនុលោមតាមដីកាសម្រេចលើសំណើរបស់ អោ អាន សុំបង្គាប់ឱ្យអង្គភាពគាំពារការការពារក្តី ផ្តល់ធនធានបន្ថែម* ថ្ងៃទី ២៤ ខែ មីនា ឆ្នាំ២០១៦។ សំណុំរឿង 00៤ ឯកសារ D304/3 *ការឆ្លើយតបរបស់អង្គភាពគាំពារការការពារក្តី ចំពោះសំណើសុំធនធានបន្ថែមរបស់មេធាវីការពារក្តី* ថ្ងៃទី ៣១ ខែ មីនា ឆ្នាំ២០១៦។

01324053



ការពារក្តី ហើយបានស្នើ អ.គ.ក និងមេធាវីការពារក្តី ឱ្យរាយការណ៍មកខ្ញុំវិញ[4]។ ខ្ញុំបានទទួលរបាយការណ៍ពីមេធាវីការពារក្តី និង អ.គ.ក នៅថ្ងៃទី ០៤ និង ០៥ ខែ ឧសភា ឆ្នាំ ២០១៦[5]។

៥. នៅថ្ងៃទី ០៩ ខែ ឧសភា ឆ្នាំ ២០១៦ ខ្ញុំបានចេញដីកាសម្រេចទី ៣ លើសំណើសុំធនធានរបស់ អោ អាន[6]។

៦. នៅថ្ងៃទី ០២ ខែ មិថុនា ឆ្នាំ ២០១៦ មេធាវីការពារក្តី យឹម ទិត្យ បានដាក់សំណើស្នើ ស.ច.ស បង្គាប់ឱ្យ អ.គ.ក ចាត់វិធានការនានាដូចជា ត្រូវផ្តល់ជូន មេធាវីការពារក្តី នូវធនធានដែលបានបែងចែកតាំងពីដើមដំបូង ("សំណើសុំធនធានរបស់ យឹម ទិត្យ")[7]។

៧. នៅថ្ងៃទី ០៧ ខែ មិថុនា ឆ្នាំ ២០១៦ ខ្ញុំបានស្នើសុំព័ត៌មានលម្អិតថែមទៀតអំពីសំណើពីមេធាវីការពារក្តី ហើយបានអញ្ជើញ អ.គ.ក ឱ្យដាក់សេចក្តីពន្យល់អំពីបញ្ហាមួយចំនួនដែលមេធាវីការពារក្តី បានចោទ[8]។ មេធាវីការពារក្តី និង អ.គ.ក បានដាក់ព័ត៌មានលម្អិតថែមទៀតនៅថ្ងៃទី ០៨ និងថ្ងៃទី ១០ ខែ មិថុនា ឆ្នាំ ២០១៦[9]។

---

[4]សំណុំរឿង ០០៤ ឯកសារ D304/4 *ដីកាសម្រេចថែមទៀតលើសំណើរបស់ អោ អាន សុំបង្គាប់ឱ្យអង្គភាពគាំពារការការពារក្តី ផ្តល់ធនធានបន្ថែម* ថ្ងៃទី ២៦ ខែ មេសា ឆ្នាំ២០១៦ ។

[5]សំណុំរឿង ០០៤ ឯកសារ D304/5 *របាយការណ៍ស្តីពីកិច្ចប្រជុំរវាងក្រុមមេធាវីការពារក្តី អោ អាន ជាមួយនឹងអង្គភាពគាំពារការការពារក្តី អនុលោមតាមដីកាសម្រេចថែមទៀតរបស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិស្តីពីធនធានបន្ថែម (ឯកសារD304/4)* ថ្ងៃទី ០៤ ខែ ឧសភា ឆ្នាំ២០១៦។ សំណុំរឿង ០០៤ ឯកសារ D304/6 *របាយការណ៍របស់ អ.គ.ក ដាក់ជូនសហចៅក្រមស៊ើបអង្កេតអន្តរជាតិ ទាក់ទងនឹងសំណើរបស់មេធាវីការពារក្តី អោ អាន សុំធនធានបន្ថែម* ថ្ងៃទី ០៥ ខែ ឧសភា ឆ្នាំ២០១៦។

[6]សំណុំរឿង ០០៤ ឯកសារ D304/7 *ដីកាសម្រេចលើសំណើរបស់ អោ អាន សុំបង្គាប់ឱ្យអង្គភាពគាំពារការការពារក្តី ផ្តល់ធនធានបន្ថែម* ថ្ងៃទី ០៩ ខែ ឧសភា ឆ្នាំ២០១៦។

[7]សំណុំរឿង ០០៤ ឯកសារ D312 *សំណើបន្ទាន់របស់ យឹម ទិត្យ សុំឱ្យសហចៅក្រមស៊ើបអង្កេត បង្គាប់អង្គភាពគាំពារការការពារក្តី ឱ្យផ្តល់ជូនក្រុមមេធាវីការពារក្តីរបស់ យឹម ទិត្យ នូវធនធានដែលបានលៃទុកពីដំបូង* ថ្ងៃទី ០១ ខែ មិថុនា ឆ្នាំ ២០១៦។

[8]សំណុំរឿង ០០៤ ឯកសារ D312/1 *ដីកាសម្រេចលើសំណើបន្ទាន់របស់ យឹម ទិត្យ ទាក់ទិននឹងធនធានរបស់ក្រុមមេធាវីការពារក្តី* ថ្ងៃទី ០៧ ខែ មិថុនា ឆ្នាំ២០១៦។

[9]សំណុំរឿង ០០៤ ឯកសារ D312/2 *ការផ្តល់ជូនព័ត៌មានបន្ថែម អនុលោមតាមឯកសារ D312/1* ថ្ងៃទី ០៨ ខែ មិថុនា ឆ្នាំ ២០១៦។ សំណុំរឿង ០០៤ ឯកសារ D312/3 *របាយការណ៍របស់អង្គភាពគាំពារការការពារក្តី ផ្ញើជូនសហចៅក្រមស៊ើបអង្កេតស្តីពីសំណើជាបន្ទាន់របស់ យឹម ទិត្យ ពាក់ព័ន្ធនឹងធនធានរបស់មេធាវីការពារក្តី* ថ្ងៃទី ១០ ខែ មិថុនា ឆ្នាំ២០១៦។

៨. នៅថ្ងៃទី ១៤ ខែ មិថុនា ឆ្នាំ ២០១៦ ខ្ញុំបានចេញដីកាសម្រេចទី ២ លើសំណើសុំធនធានរបស់ យឹម ទិត្យ[10]។

៩. នៅថ្ងៃទី ២៨ ខែ កក្កដា ឆ្នាំ ២០១៦ មេធាវីការពារក្តី អោ អាន និងមេធាវីការពារក្តី យឹម ទិត្យ (ហៅកាត់រួមថា "មេធាវីការពារក្តីសំណុំរឿង ០០៤") បានដាក់សំណើរួមសុំធ្វើចំណាត់ថ្នាក់ឯកសារឡើងវិញចំពោះដីកាសម្រេច និងឯកសារពាក់ព័ន្ធទាំងអស់ទាក់ទងនឹងសំណើសុំធនធានរបស់ អោ អាន និង យឹម ទិត្យ ("សំណើ")[11]។

១០. នៅថ្ងៃទី ០៣ ខែ សីហា ឆ្នាំ ២០១៦ សហព្រះរាជអាជ្ញាអន្តរជាតិ បានជូនដំណឹងបុគ្គលិករបស់ខ្ញុំ ថា សហព្រះរាជអាជ្ញា មិនមានបំណងដាក់ចម្លើយតបទៅនឹងសំណើឡើយ។

## II. **សារណា**

១១. មេធាវីការពារក្តីសំណុំរឿង០០៤ ស្នើថា ខ្ញុំគួរធ្វើចំណាត់ថ្នាក់ឯកសារឡើងវិញដោយប្តូរពី "សម្ងាត់"ទៅ"សាធារណៈ"ចំពោះឯកសារចំនួន១០ ទាក់ទងនឹងសំណើសុំធនធានរបស់អោ អាន និងយឹម ទិត្យ ដែលបានលើកយោងនៅកថាខណ្ឌ២ នៃសំណើ("ឯកសារ")បើមិនអញ្ចឹងទេខ្ញុំគួរតែដាក់ឯកសារទាំងនេះចូលក្នុងសំណុំរឿងទាំងអស់ដែលកំពុងដំណើរការយ៉ាងសកម្ម[12]។

១២. មេធាវីការពារក្តីសំណុំរឿង ០០៤ អះអាងថា ការធ្វើចំណាត់ថ្នាក់ឯកសារឡើងវិញដាក់ទៅជា "សាធារណៈ"នឹងមិនប៉ះពាល់ដល់ការស៊ើបអង្កេតឡើយ ពីព្រោះថា ឯកសារទាំងនោះមិនពាក់ព័ន្ធផ្ទាល់ជាមួយនឹងអង្គហេតុដែលកំពុងស៊ើបអង្កេតឡើយ[13]។ ក្នុងករណីដែលព័ត៌មានមិនមានភាពពាក់ព័ន្ធខ្លាំងជាមួយនឹងអង្គហេតុដែលកំពុងស៊ើបអង្កេត មេធាវីការពារក្តីសំណុំរឿង ០០៤ ផ្តល់ទឡ្ហីករណ៍ថា ព័ត៌មាននេះមិនគួររក្សាទុកជាព័ត៌មានសម្ងាត់ឡើយ[14]។

---

[10] សំណុំរឿង ០០៤ ឯកសារ D312/4 *ដីកាសម្រេចទី ២ លើសំណើបន្ទាន់របស់ យឹម ទិត្យ ទាក់ទងនឹងធនធានបន្ថែមរបស់មេធាវីការពារក្តី* ថ្ងៃទី ១៤ ខែ មីនា ឆ្នាំ២០១៦។

[11] សំណុំរឿង ០០៤ ឯកសារ D304/9 *សំណើរួមរបស់ក្រុមមេធាវីការពារក្តី សុំឱ្យដាក់ចំណាត់ថ្នាក់ឯកសារជាថ្មីចំពោះសេចក្តីសម្រេច និងការដាក់សារណាពាក់ព័ន្ធនឹងធនធាន* ថ្ងៃទី ២៨ ខែ កក្កដា ឆ្នាំ២០១៦។

[12] សំណើ កថាខណ្ឌ ២-៣។

[13] សំណើ កថាខណ្ឌ ២៧ និង ២៨។

[14] សំណើ កថាខណ្ឌ ២៨។

១៣. មេធាវីការពារក្តីសំណុំរឿង ០០៤ អះអាងថា ឯកសារទាំងនោះគឺពាក់ព័ន្ធនឹងសេចក្តីសម្រេចលើបញ្ហាការជំនុំជម្រះក្តីដោយយុត្តិធម៌ និងបញ្ហារដ្ឋបាល ហើយគួរដាក់បង្ហាញស្របតាមគោលការណ៍យុត្តិធម៌ និងតម្លាភាព ដូចបានកំណត់នៅក្នុងវិធានផ្ទៃក្នុង ២១(១)[15]។ មេធាវីការពារក្តីសំណុំរឿង ០០៤ អះអាងថា ការធ្វើចំណាត់ថ្នាក់ឯកសារឡើងវិញនេះនឹងជួយធានាថា បញ្ហាស្រដៀងគ្នានេះដែលកើតឡើងនាពេលអនាគត ត្រូវដោះស្រាយស្របតាមគោលការណ៍ដែលបានបង្កើតឡើងរួចហើយនៅក្នុងដីកាសម្រេចរបស់ខ្ញុំ លើសំណើសុំធនធានរបស់ អោ អាន និង យឹម ទិត្យ ហេតុនេះបានការពារសិទ្ធិរបស់ជនត្រូវចោទ ក្នុងការទទួលបានការជំនុំជម្រះក្តីដោយយុត្តិធម៌ និងសិទ្ធិទទួលបានពេលវេលា និងសម្ភារៈរូបវន្តគ្រប់គ្រាន់[16]។

## II. ពិភាក្សា

១៤. សំណើ ធ្វើឱ្យច្របូកច្របល់រវាងតម្លាភាពជាមួយនឹងការផ្សព្វផ្សាយជាសាធារណៈ។ នៅពេលនេះ មិនអាចយល់ឃើញថា សាធារណជន ចាប់អារម្មណ៍ចង់ដឹងអំពីលក្ខខណ្ឌសម្រាប់បែងចែកធនធានទៅមេធាវីការពារក្តី ឡើយ។

១៥. ស.ច.ស មានឆន្ទានុសិទ្ធិទូលំទូលាយដើម្បីធ្វើចំណាត់ថ្នាក់ឯកសារឡើងវិញចំពោះឯកសារដែលបានដាក់មក ឬធ្វើឡើងនៅក្នុងអំឡុងពេលស៊ើបសួរ។ មិនដូចនៅដំណាក់កាលជំនុំជម្រះក្តីឡើយ ចំពោះដំណាក់កាលស៊ើបសួរ តាមវិធានគឺថា អ្វីទាំងអស់គឺជាការសម្ងាត់។ ម្យ៉ាងទៀត ជាគោលការណ៍ សាធារណជន មិនមានសិទ្ធិដឹងអំពីភាពលម្អិតនៃកិច្ចស៊ើបសួរឡើយ។

១៦. អាចមានករណីលើកលែងប្រសិនបើផលប្រយោជន៍សាធារណៈមានសារៈសំខាន់ជាង និងមានយុត្តិកម្មចំពោះការធ្វើចំណាត់ថ្នាក់ឯកសារឡើងវិញ។ ខ្ញុំមិនអាចយល់ឃើញថា សាធារណជន នឹងចាប់អារម្មណ៍លើបញ្ហារដ្ឋបាលបែបនេះឡើយ ដែលបញ្ហាបែបនេះអាចសំខាន់សម្រាប់ក្រុមមេធាវីការពារក្តី។ នៅពេលនេះ ក៏មិនមានទឡ្ហីករណ៍ត្រូវធ្វើចំណាត់ថ្នាក់ឯកសារឡើងវិញឡើយតាមលក្ខខណ្ឌផ្នែកអប់រំ ឬកេរដំណែល។

---

[15] សំណើ កថាខណ្ឌ ២៧, ២៩ និង ៣០។

[16] សំណើ កថាខណ្ឌ ៣២។

១៧. ស្ថានភាពបច្ចុប្បន្ននេះបានផ្តល់ជូនតម្លាភាពពេញលេញរួចហើយសម្រាប់ជនទាំងអស់ដែលត្រូវជាប់ពាក់ព័ន្ធ។ តម្លាភាពនៃដំណើរការនីតិវិធី គឺមិនដូចគ្នានឹងការផ្សព្វផ្សាយជាសាធារណៈឡើយ ជាពិសេសប្រសិនបើលក្ខខណ្ឌស្តីពីកំហុសនីតិវិធីគឺជាការសម្ងាត់។ អ.ត.ក ដឹងពីគោលជំហររបស់ ស.ច.ស.អន្តរជាតិ ហើយមានការរំពឹងទុកថា អ.ត.ក ត្រូវអនុវត្តតាមគោលជំហរនេះ ចំណែកឯ ភាគីនៅក្នុងសំណុំរឿង ០០៤ ក៏ដឹងពីគោលជំហរនេះដែរ។ ជាធម្មតា ខ្ញុំនឹងអនុវត្តគោលការណ៍ដូចគ្នានេះនៅក្នុងសំណុំរឿង ០០៣ នៅពេលដែលបញ្ហានេះកើតឡើង។

១៨. ខ្ញុំក៏កត់សម្គាល់ថា រឿងក្តីនីមួយៗផ្តោតសំខាន់លើអង្គហេតុនៃរឿងក្តីនោះ ហើយប្រសិនបើផ្សព្វផ្សាយឯកសារទាំងនោះជាសាធារណៈ ក៏នឹងមិនអាចកំណត់បានជាមុនអំពីលទ្ធផលជាក់ស្តែងនៃសំណើណាមួយដែលដាក់នៅពេលនាអនាគតដែរ។

១៩. ជាចុងក្រោយ ភាគីនៅក្នុងសំណុំរឿង ០០៤ មិនមានសិទ្ធិប្តឹងតវ៉ា តាងនាមឱ្យភាគីនៅក្នុងសំណុំរឿង ០០៣ ឡើយ ជាពិសេសមេធាវីការពារក្តី។ ក្នុងករណីដែលមានការដាក់ឯកសារពីមេធាវីការពារក្តីនៅក្នុងសំណុំរឿង ០០៣ សំណៅកោសលុបនៃឯកសារចាំបាច់នានា ឧទាហរណ៍ដូចជា ដីកាសម្រេចសម្ងាត់ពីមុនៗនៅក្នុងសំណុំរឿង ០០៤ នឹងដាក់ភ្ជាប់មកជាមួយនឹងដីកាសម្រេចលើការដាក់ឯកសារនោះដូចបានអនុវត្តរហូតមកដល់សព្វថ្ងៃនេះ។ មេធាវីការពារក្តី នៅក្នុងសំណុំរឿង ០០៤ មិនទទួលរងផលប៉ះពាល់ដោយសារការរក្សាទុកចំណាត់ថ្នាក់ឯកសារបច្ចុប្បន្ននេះឡើយ ពីព្រោះថា ខ្លួនអាចចូលពិនិត្យមើលឯកសារទាំងនោះបាន។

**តាមសំអាងហេតុខាងលើ ខ្ញុំ ៖**

២០. **បដិសេធ** សំណើ។

ភ្នំពេញ ថ្ងៃទី ៣១ ខែ សីហា ឆ្នាំ ២០១៦

**ចៅក្រម Michael Bohlander**

**សហចៅក្រមស៊ើបអង្កេតអន្តរជាតិ**

**International Co- Investigating Judge**

**Co-juge d'instruction International**